សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០២ លេខ ២៤៩ ចេញផ្សាយថ្ងៃ អាទិត្យ_អង្គារ ទី ២១_២៣ ខែ កញ្ញា ឆ្នាំ ២០០៨

## សម រង្ស៊ី មានជំនឿលើសម្ដេចឪក្នុងការដោះស្រាយបញ្ហាជាមួយសៀមនិងការជាប់គាំងនយោបាយ



ព្រះករុណាសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រនៃកម្ពុជា



លោក សម រង្ស៊ី

ដោយៈ រតនៈ

ប្រធានគណបក្សប្រឆាំងនៃប្រទេសកម្ពុជាលោក*សម រង្ស៊ី* កាលពីថ្ងៃទី១៩ កញ្ញា ២០០៨ បានសរសេរលិខិត ទូលថ្វាយសម្ដេចឪ ព្រះ*នរោត្តម សីហនុ* អំពីរដ្ឋាភិបាលខ្មែរ ដែលដឹកនាំដោយគណបក្សប្រជាជន ថា

តទៅទំព័រ២ ស

## នួន ជា ត្រូវឃុំខ្លួន១ឆ្នាំទៀតមុននឹងមានការកាត់ទោសតាមបទចោទប្រកាន់ដ៏មហាឧក្រិដ្ឋ



មេធាវី សុន អារុណ



នួន ជា អតីតបងធំទី២នៃរបបខ្មែរក្រហមប្រល័យពូជសាសន៍

ដោយ : គ.រដ្ឋា

*នួន ជា* អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យហៅខ្មែរក្រហមត្រូវបានចាប់ឃុំជាបណ្ដោះអាសន្ននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអស់រយៈពេល១ឆ្នាំមកហើយ បើគិតត្រឹមថ្ងៃទី១៩

តទៅទំព័រ២ ខ

## ឆាកល្ខោនជនល្មោភអំណាច ហ៊ុន សែន_រណឫទ្ធិខ្មែរជ្រើញហើយ



នាយករដ្ឋមន្ត្រី ហ៊ុន សែន និងព្រះរាជបុត្រកំពូលល្បិច នរោត្តម រណឫទ្ធិ

ដោយ : ជ.ឧត្តម

មានតែមនុស្សធ្លាក់មកពីលើមេឃទេទើបគេមិនដឹងថាលោក *ហ៊ុន សែន* និងទ្រង់*រណឫទ្ធិ* ជាមនុស្សប្រភេទណានោះ តែបើសម្រាប់ប្រជាពលរដ្ឋខ្មែរវិញទោះបីជាអ្នកទាំងពីរនេះសម្ដែងល្ខោនក្នុងរឿងអ្វីក៏

តទៅទំព័រ២ គ

## មហិច្ឆតា របស់ គណបក្ស សម រង្ស៊ី គឺចង់ឱ្យរាស្ត្រមានជីវភាពធូរធារនិងគ្មានអ្នករំលោភរាស្ត្រប៉ុណ្ណោះ

### ព្រះបរមរាជវាំងអាចស្នើអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីឱ្យចូលស្បថនៅថ្ងៃទី២៤កញ្ញាដែរតែខុសពេលគ្នា



សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រខ្មែរ



លោក យឹម សុវណ្ណ



លោក អេង ឆៃអ៊ាង



លោកស្រី មូរ សុខហួរ



លោក នុត រុំដួល



លោកស្រី ជូឡុង សូមួរ៉ា



លោក ម៉ៅ មុនីវណ្ណ

ដោយ : ស្សាវរីយ៍

សង្គ្រាមពាក្យសម្ដី រវាងមេដឹកនាំគណបក្សប្រជាជន ដែលបង្កើតឡើងដោយយួន បំរើឱ្យប្រយោជន៍បរទេសជាមួយថ្នាក់ដឹកនាំគណបក្សសម រង្ស៊ី ពាក់ព័ន្ធនឹងថ្ងៃប្រជុំសភាដំបូង និងការស្បថ ចូលកាន់តំណែងនេះ បានធ្វើឱ្យមន្ត្រី គណបក្សប្រជាជន រិះគន់សមាជិកសភាគណបក្សសមរង្ស៊ីថាការធ្វើពហិកា

តទៅទំព័រ៤ ម

## រឿងទាហានសៀមឈ្លានពានដីខ្មែរដោះមិនចេញទំនងជាជាប់កិច្ចសន្យារកស៊ីសម្ងាត់រវាង ថាក់ស៊ីន និង ហ៊ុន សែន ទេដឹង?



លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោក ហ៊ុន សែន



លោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា

ដោយ : គ.អរពិន្ទ

បញ្ហានៃការរំលោភឈ្លានពានកាន់កាប់ដីខ្មែរដោយពួកទាហានប្រដាប់អាវុធសៀមចាប់តាំងពីពាក់កណ្ដាលខែកក្កដាមកដល់ពេលនេះ នៅតែស្ទុះស្ទាញដោះស្រាយមិនចេញ។ បើយោងតាមសារព័ត៌មានបរទេសមួយចំនួននោះ បញ្ហាស្ទុះស្ទាញនេះក៏ដោយសារតែមានកិច្ចសន្យារកស៊ីសម្ងាត់រវាង

តទៅទំព័រ៤ ន

## ពលរដ្ឋសៀមខ្លះធុញទ្រាន់នឹងស្ដេចខ្លួន

ដោយ : សច្ចៈ

រយៈពេល ចុងក្រោយនេះប្រទេសសៀម បានកើតមាននូវភាពវឹកវរជាបន្តបន្ទាប់ដែលបានបង្កឡើងដោយក្រុម អ្នកគាំទ្រព្រះមហាក្សត្រ *ភូមិពល អឌុលយាដេត* មួយក្រុមតូច។ ភាពវឹកវរ ដែលកំពុងរុញច្រានប្រទេសនេះ អោយមានវិបត្តិ

តទៅទំព័រ៣ ឃ

## សៅ សុខា ហ៊ានចាត់ការក្លឹបល្បែងស៊ីសងរបស់ រស់ ជៀវ កាងដោយប៉េអឹម អ៊ុក អឿន ដែរឬទេ?



ឧត្តមសេនីយ៍ សៅ សុខា



ពួកលេងល្បែងយុគីនៅក្លឹបល្បែងស៊ីសងរបស់លោក រស់ ជៀវ

ដោយ : យុទ្ធ ពន្សា

ក្រុមអ្នកចាញ់ល្បែងស៊ីសងនៅក្នុងក្លឹបលោក *រស់ ជៀវ* នៅក្រុងព្រះសីហនុដែលមានលោកប៉េអឹម *អ៊ុក អឿន* ចាំការពារពីក្រោយខ្នងនោះ បានរាយការណ៍មកថា ក្លឹបល្បែងរបស់ទាហាន *រស់ ជៀវ* នេះនៅតែ

តទៅទំព័រ៣ ជ

## ដំណឹងលក់ដីឡូត៍

**យើងខ្ញុំមានដីឡូត៍លក់ ទំហំ 5m x 14m តម្លៃ 3600$ និងទំហំ 4.50m x 14m តម្លៃ 2700$ ផ្លូវ៧ម៉ែត្រ ក្រាលគ្រួសក្រហម ដែលមានទីតាំងស្ថិតនៅភូមិ ត្រពាំងប្រុយ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល (ជាប់របងរោងចក្រ ចូលតាមច្រក ផ្សារបែកចាន)។**

**សូមទំនាក់ទំនងទូរស័ព្ទលេខ : 012 920 500 , 011 73 62 77**

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្អំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្ដី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្ប៉ែត ព្យាបាល យ៉ាងស័ក្ដិសិទ្ធ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្ពាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : **012 363 331, 016 719 616,**

## *បរិយាយថ្ងៃនេះ*

### មួយខែៗអ្នកកាន់អំណាចនៅកម្ពុជាបញ្ចេញលុយរដ្ឋស្ងាត់ៗ៣០លានដុល្លារចែកប្រយោជន៍ជាមួយក្រុមហ៊ុនប្រេង

ដោយ : ហង្ស ធ្រាដ្ឋា

ទើបតែប៉ុន្មានថ្ងៃមុននេះប៉ុណ្ណោះដែលគេបានឮសម្ដីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរំលឹកលើកនិយាយតាមរបៀបកេងចំណេញនយោបាយប្រជាភិថុតិពីប្រជារាស្ត្រខ្មែរអំពីរឿងប្រេងសាំងឡើងថ្លៃនោះ។ គាត ឈន់ បាននិយាយថា តម្លៃប្រេងនៅកម្ពុជាត្រូវតែធ្លាក់ចុះមកនៅត្រឹម

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ខ**

ខែកញ្ញាកន្លងទៅ ។ តែឈ្មោះ *នួន ជា* នេះត្រូវបានតុលាការសម្រេចពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន១ឆ្នាំទៀតដោយយោងតាមវិធានផ្ទៃក្នុង របស់សាលាក្ដីខ្មែរក្រហម ។

ក្រុមមេធាវីការពារ *នួន ជា* បានអះអាងថា បានសម្រេចដាក់ពាក្យបណ្ដឹងទៅអង្គបុរេជំនុំជម្រះហើយ ដើម្បីប្រឆាំងនឹងដីកាបន្តការឃុំខ្លួនកូនក្ដីពួកគេរយៈពេល១ឆ្នាំទៀត ដោយចាត់ទុកថា នេះជាការរំលោភសិទ្ធិកូនក្ដីរបស់ខ្លួន ។

គួរបញ្ជាក់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ឃុំខ្លួនជនជាប់ចោទចំនួន៥នាក់ដែលសុទ្ធតែជាអតីតមេដឹកនាំសំខាន់ៗនៃរបបខ្មែរក្រហម និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវរងនូវការចោទប្រកាន់យ៉ាងកងរំពងថា បានធ្វើឱ្យប្រជាពលរដ្ឋស្លូតត្រង់ស្លាប់រង្គាលអស់ជិត២លាននាក់ពីចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។

*នួន ជា* អាយុ៨២ឆ្នាំជាអតីតមេដឹកនាំខ្មែរក្រហមលំដាប់ទីពីរក្នុងចំណោមមេដឹកនាំខ្មែរក្រហមដទៃទៀតដែលកំពុងជាប់ឃុំខ្លួនរង់ចាំការកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ សហចៅក្រមស៊ើបអង្កេតបានពន្យារពេលឃុំខ្លួន *នួន ជា* ១ឆ្នាំទៀតមុននឹងបញ្ជូនខ្លួនទៅកាត់ទោសដែលការធ្វើបែបនេះត្រូវបានក្រុមមន្ត្រីសាលាក្ដីខ្មែរក្រហមអះអាងថា តាមវិធានផ្ទៃក្នុងចៅក្រមមានសិទ្ធិពន្យារពេល១ឆ្នាំម្ដងៗរហូតដល់៣ឆ្នាំដើម្បីស៊ើបអង្កេតប្រសិនបើករណីនេះពុំទាន់ពេញលេញ ឬក៏មិនអាចបញ្ចប់បាននោះ ។

ក្រុមអ្នកតាមដានដំណើរការសាលាក្ដីខ្មែរក្រហមបានសម្ដែងនូវការធុញទ្រាន់ថា ដូចជាពុំមានការជឿនលឿនអ្វីបន្តិចសោះ ព្រោះតាំងពីថ្ងៃចាប់ខ្លួន *នួន ជា* មក គឺមានតែចេញដីកាឃុំខ្លួន, ប្ដឹងឧទ្ធរណ៍ និងដឹកទៅមន្ទីរពេទ្យញឹកញាប់ រួចចេញដីកាឃុំខ្លួនបន្តទៀត និងប្ដឹងឧទ្ធរណ៍បន្តទៀត ដែលសកម្មភាពបែបនេះវាមិនខុសអ្វីពីការដើរទៅមុខមិនរួចនោះទេ ។

កន្លងមកអ្វីដែលសាលាក្ដីខ្មែរក្រហមត្រូវការបំផុតដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនោះ គឺថវិកាទ្រទ្រង់សាលាក្ដីឱ្យដំណើរការតទៅទៀតបាន ព្រោះថ្ងៃណាក៏ដូចថ្ងៃណាដែរគឺសាលាក្ដីនេះថ្ងូររហូតពីរឿងខ្វះខាតថវិកា ។

កាលពីថ្ងៃទី១៦ ខែកញ្ញាកន្លងទៅ លោកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក John Negroponte បានឱ្យដឹងថាក្រសួងការបរទេសអាមេរិកមានបំណងនឹងធ្វើការពិភាក្សាជាមួយសភាដើម្បីផ្ដល់ថវិកាជាលើកដំបូងចំនួន១,៨ លានដុល្លារដល់សាលាក្ដីខ្មែរក្រហម ។

មិនតែប៉ុណ្ណោះលោកឧបការីរូបនេះបានអះអាងថា "*យើងសង្ឃឹមថា នឹងចូលរួមយ៉ាងសកម្មជាមួយក្រុមប្រទេសផ្ដល់ជំនួយដទៃទៀតដើម្បីឱ្យសាលាក្ដីខ្មែរក្រហមប្រព្រឹត្តទៅបានចប់ចុងចប់ដើម និងមានការគ្រប់គ្រងត្រឹមត្រូវថែមទៀតផង*" ។

ជាមួយគ្នានេះដែរ លោក John Negroponte បានសង្កត់ធ្ងន់ថា នឹងមានការដោះស្រាយឱ្យបានជ្រះស្រឡះនូវអំពើពុករលួយនិងការគ្រប់គ្រង ។សំខាន់គឺជាសេចក្ដីសម្រេចដើម្បីរៀបចំគម្រោងថវិកាសម្រាប់សាលាក្ដីខ្មែរក្រហមបានបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់សហរដ្ឋអាមេរិកក្នុងការជួយដល់ដំណើរការសាលាក្ដីខ្មែរក្រហមឱ្យប្រកបដោយជោគជ័យជាស្ថាពរ ។ហើយនៅទីបញ្ចប់ប្រជាពលរដ្ឋកម្ពុជាអាចនឹងកសាងបាននូវសង្គមមួយមាននីតិរដ្ឋ ។

បានសេចក្ដីថាជំនួយសម្រាប់សាលាក្ដីខ្មែរក្រហមគឺសហរដ្ឋអាមេរិកនឹងជួយ តែក៏មានការបង្ហាញឱ្យឃើញថា សាលាក្ដីនេះគ្មានអំពើពុករលួយ ហើយការគ្រប់គ្រងត្រូវតែដោះស្រាយឱ្យជ្រះស្រឡះ ។

នេះជាក្ដីសង្ឃឹមថ្មីមួយទៀតរបស់សាលាក្ដីខ្មែរក្រហមខណៈដែលមូលនិធិសហរដ្ឋអាមេរិកនឹងត្រូវផ្ដល់មកឱ្យសាលាក្ដីខ្មាតអន្តរជាតិមួយនេះជាមួយនឹងការប្រឈមយ៉ាងធ្ងន់ធ្ងរអំពីកិរិយាមិនត្រឹមត្រូវ និងអំពើពុករលួយនៅខាងភាគីកម្ពុជា ។

ការចោទប្រកាន់ពីអំពើពុករលួយនេះស្ថិតក្រោមការត្រួតពិនិត្យដោយសាខាអធិការកិច្ចទូទៅរបស់សហប្រជាជាតិក្នុងក្រុងញូវយ៉ក ។

ភាគីសហប្រជាជាតិរបស់សាលាក្ដីនេះក៏អស់ប្រាក់ផងដែរមុនដំណាច់ឆ្នាំ២០០៨ ។ចំណែកភាគីកម្ពុជាពេលនេះត្រូវបានផ្ដល់មូលនិធិត្រឹមតែខែមីនាកន្លងមកប៉ុណ្ណោះ ហើយក៏គ្មានការផ្ដល់វិភាគទានបន្ថែមទៀតទេបន្ទាប់ពីមានការចោទប្រកាន់ថាមានអំពើពុករលួយត្រូវបានផ្សព្វផ្សាយជាសាធារណៈតាំងតែពីខែសីហាឆ្នាំ២០០៧មក ។

គួរបញ្ជាក់ថា កន្លងមកសមាជិកសភាអាមេរិកបានជំទាស់ដាច់ខាតមិនផ្ដល់មូលនិធិឱ្យតុលាការកូនកាត់នេះទេដោយរង់ចាំសេចក្ដីសម្រេចពីក្រសួងការបរទេសអាមេរិកថាប្រព័ន្ធតុលាការនៅកម្ពុជាមានសមត្ថភាពពេញលេញ និងចាកផុតពីអំពើពុករលួយ និងឥទ្ធិពលនយោបាយ ។ ហើយថាតុលាការនោះត្រូវតែអនុវត្តន៍ទៅតាមស្តង់ដារកាត់ទោសត្រឹមត្រូវជាអន្តរជាតិ ។

ពេលនេះបើយោងតាមប្រសាសន៍លោក John Negroponte ឧបការី រដ្ឋមន្ត្រីការបរទេសអាមេរិកស្ដីពីការផ្ដល់ជំនួយជាលើកដំបូងដល់សាលាក្ដីខ្មែរក្រហម ក្រោយពីការជួបពិភាក្សាជាមួយសភាអាមេរិកាំងហើយនោះ គឺមជ្ឈដ្ឋានជាទូទៅសង្ឃឹមថា ដំណើរការសាលាក្ដីខ្មែរក្រហមនឹងឈានទៅមុខទៀតក្រោមការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់របស់អាមេរិកហើយ ។

បើគិតអំពីរយៈពេលនេះសាលាក្ដីខ្មែរក្រហមត្រូវបានគេរិះគន់កប់ៗមាត់ថា ចាយវាយលុយកាក់អស់មួយគំនរទៅហើយ តែពុំទាន់បានកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមណាម្នាក់តាមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ។

មជ្ឈដ្ឋានជាទូទៅបានសម្ដែងនូវការព្រួយបារម្ភថា អតីតមេដឹកនាំខ្មែរក្រហមមានវ័យកាន់តែចាស់ជរាណាស់ទៅហើយ បើសាលាក្ដីខ្មែរក្រហមធ្វើការយឺតយ៉ាវបែបនេះទំនងជាមានការកាត់ទោសគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះក៏អាចថាបានដែរ ៕

**តមកពីទំព័រ១ គ**

ដោយ ក៏នៅតែស្គាល់ថាជាជនល្មោភអំណាចមិនចេះស្កប់ស្កល់ដែរ ។

គួររំលឹកថា មុននឹងលោក *ហ៊ុន សែន* សុខចិត្តបន្ទន់តំរិយាបថដាក់ទ្រង់ *រណឫទ្ធិ* នោះ គឺលោក*ហ៊ុន សែន* បាន "*សាប់*" ទ្រង់ *រណឫទ្ធិ* បែកទឹកសំពោងតាំងពីទ្រង់ *រណឫទ្ធិ* នៅគង់ជាប្រធានរដ្ឋសភាម្ល៉េះ ។

ដោយសារទ្រង់ *រណឫទ្ធិ* មានចំណុចខ្សោយមិនហ៊ាន "*សាប់*" លោក *ហ៊ុន សែន* ឱ្យហុយដីសំពោងវិញនោះ ទើបធ្វើឫកសុំលាលែងពីតំណែងប្រធានរដ្ឋសភា និងបានអះអាងថា ចុះទៅពង្រឹងហ៊្វុនស៊ិនប៉ិចនៅមូលដ្ឋាន ដើម្បីស្ដារប្រជាប្រិយភាពហ៊្វុនស៊ិនប៉ិចឡើងវិញ ។

ប៉ុន្តែទ្រង់ *រណឫទ្ធិ* មិនបានប្រតិបត្តិទៅតាមបន្ទូលរបស់ទ្រង់ឯណាពោលគឺទ្រង់សុខចិត្តនាំនាង *អ៊ុក ផល្លា* ទៅសោយសុខនៅក្រៅប្រទេសដោយទុកឱ្យហ៊្វុនស៊ិនប៉ិចដែលជាកេរមរតកដ៏មានតម្លៃជាប្រវត្តិសាស្ត្ររបស់សម្ដេចព្រះ *នរោត្ដម សីហនុ* ទទួលរងនូវការកកូរកកាយផ្ទៃក្នុងដោយលោក *ហ៊ុន សែន* យ៉ាងជូរចត់បំផុត ។

មជ្ឈដ្ឋានជាទូទៅក៏មើលឃើញនូវស្ថានការណ៍ដួលរលំរបស់ហ៊្វុនស៊ិនប៉ិចដែរ បន្ទាប់ពីទ្រង់ *រណឫទ្ធិ* សុខចិត្តទ្រាំរស់ទាំងអាម៉ាស់នៅក្រៅប្រទេសនោះ តែបើសម្រាប់អ្នកវិភាគវិញគេបានដៅក្រឡារួចជាស្រេចថា ហ៊្វុនស៊ិនប៉ិចនឹងត្រូវលោក*ហ៊ុនសែន*បំបែកទាល់តែខ្ទេច ។ ហើយការបំបែកលើកនេះគឺធ្វើឱ្យទ្រង់*រណឫទ្ធិ*ទៅបង្កើតគណបក្សថ្មីមួយដោយគ្រាន់តែអូសទាញកម្លាំងពីហ៊្វុនស៊ិនប៉ិចឱ្យចុះខ្សោយទៅៗតែប៉ុណ្ណោះ ។

គេនៅចាំបានថា ក្នុងនាមជាប្រធានគណបក្សនរោត្ដម រណឫទ្ធិ ទ្រង់ *រណឫទ្ធិ* ដ៏មហាកំហូចរកលេខដាក់គ្មាន ដែលគង់តែក្រៅប្រទេសជាមួយនាង *អ៊ុក ផល្លា* នេះ បានព្យាយាមប្រកូកប្រកាសអំពាវនាវឱ្យគណបក្សសមរង្ស៊ី, គណបក្សសិទ្ធិមនុស្ស រួមគ្នាជាមួយគណបក្សនរោត្ដម រណឫទ្ធិ របស់ទ្រង់ដើម្បីបង្កើតជាគណបក្សដ៏ធំមួយសម្រាប់តទល់នឹងគណបក្សប្រជាជនរបស់លោក *ហ៊ុន សែន* ប៉ុន្តែគ្មានអ្នកនយោបាយណាស្ដាប់ការអូសទាញរបស់ទ្រង់ *រណឫទ្ធិ* នោះទេ ។

ព្រោះអ្វី ? ព្រោះគេដឹងថាទ្រង់ *រណឫទ្ធិ* ពិតជាមិនចោលក្បួន "*ដិះក្របីចម្លងផុក*" នោះទេ ។ ហើយក្បួនខិលខូចបង្កប់ដោយពុតត្បុតដ៏អាស្រូវបែបនេះក៏ប្រាកដជាគ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គបានឡើយ ។

ទីបំផុតទ្រង់ *រណឫទ្ធិ* ដែលពោរពេញទៅដោយមហិច្ឆតាអំណាចមិនស្កប់ស្កល់នោះ បានទទួលរងនូវ ការបរាជ័យយ៉ាងអាម៉ាស់ ពោលគឺបានតែ២ជើងម៉ាប៉ុណ្ណោះនៅក្នុងសភា ។

គេថា ទ្រង់ *រណឫទ្ធិ* ហាក់ដូចជាគ្មានការឈឺចាប់ទាល់តែសោះចំពោះលទ្ធផលឆ្នោតបែបនេះ ព្រោះនៅពេលដែលលោក *មុត ចន្ថា* មកចូលរួមជាមួយគណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្ស ប្រឆាំងនឹងលទ្ធផលឆ្នោតដែលមានភាពមិនប្រក្រតីយ៉ាងច្រើនសន្ធឹកសន្ធាប់នោះស្រាប់តែស្ងាត់ៗទ្រង់*រណឫទ្ធិ* សរសេរជាលិខិតអបអរសាទរនឹងលទ្ធផលឆ្នោតហើយជម្រុញឱ្យលោក *ហ៊ុន សែន* បង្កើតរដ្ឋាភិបាលថ្មីឆាប់ៗទៅវិញ ។

ដោយសារទ្រង់ *រណឫទ្ធិ* ផ្លាស់ប្ដូរជំហរយ៉ាងឆាប់រហ័សដូចផ្លេកបន្ទោរបែបនេះហើយ ទើបប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសកាន់តែស្ញើចសរសើរជំហរនិងភាពឈ្លាសវៃរបស់លោក*សម រង្ស៊ី* និងលោក*កឹម សុខា* ថែមទៀត ព្រោះប្រសិនបើអ្នកប្រជាធិបតេយ្យទាំងពីរនេះលង់ខ្លួនជឿតាមបន្ទូលបោកប្រាស់របស់ទ្រង់ *រណឫទ្ធិ* ទៀតនោះប្រាកដជាស្រឡះដៃធេងនៅក្នុងអាណត្តិទី៤នេះតែម្ដង ។

តាមពិតទៅប្រជាពលរដ្ឋខ្មែរកំពុងតែមានមន្ទិលសង្ស័យថា ទ្រង់ *រណឫទ្ធិ* ក៏ជាតួអង្គបំបែកបំបាក់កម្លាំងប្រជាធិបតេយ្យម្នាក់ដែរ តែទ្រង់លាក់មុខនៅក្នុងស្រោមអ្នកប្រជាធិបតេយ្យផង, អ្នករាជានិយមផង ទើបបានជាគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សនរោត្ដមរណឫទ្ធិសំយុងក្បាលចុះដល់ថ្នាក់ហ្នឹង ។

ប៉ុន្តែអ្នកខ្លះទៀតដែលនៅតែមានជំហរស្វាមីភក្តិចំពោះទ្រង់ *រណឫទ្ធិ* នោះ បានលើកឡើងថា មកពីទ្រង់ស្លូតពេក, ត្រង់ពេក ទើបចេះតែលង់ខ្លួនចាញ់បោកលោក *ហ៊ុន សែន* ម្ដងហើយម្ដងទៀតយ៉ាងដូច្នេះ ។

ការលើកឡើងបែបនេះត្រូវបានជំទាស់ដោយក្រុមអ្នកអស់ជំនឿលើទ្រង់ *រណឫទ្ធិ* ថា ព្រះរាជបុត្រកំពូលបោកប្រាស់

**តនៅទំព័រ៣ គ**

**តមកពីទំព័រ១ ស**

គ្មានសមត្ថភាព ដោះស្រាយបញ្ហាបូរណភាពទឹកដី ជាមួយប្រទេសសៀម, ហើយមានតែអង្គសម្ដេចឪប៉ុណ្ណោះដែលមានសមត្ថភាព ព្រមទាំងអាចដោះស្រាយភាពជាប់គាំង នយោបាយនៅកម្ពុជាផងដែរ ។

លិខិតលោកសម *រង្ស៊ី* មានខ្លឹមសារថា "*ទូលបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាត ក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តាជ្រាបថា បច្ចុប្បន្ននេះប្រទេសថៃ នៅតែបន្តរំលោភមកលើអធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជារៀងរាល់ថ្ងៃឥតឈប់ឈរ ហើយរាជរដ្ឋាភិបាលខ្មែរហាក់ដូចជា ពុំមានសមត្ថភាពដោះស្រាយបញ្ហានេះឡើយ ។ ទន្ទឹមនឹងនេះ វិបត្តិនយោបាយក្នុងប្រទេសនៅតែបន្ត ដោយសារភាពមិនប្រក្រតី ជាច្រើនក្នុងការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រថ្ងៃទី២៧ កក្កដា ២០០៨ មិនបានទទួលដំណោះស្រាយត្រឹមត្រូវ ។ បញ្ហាប្រឈមគួរឱ្យព្រួយបារម្ភទាំងនេះទូលព្រះបង្គំយល់ឃើញថាមានតែព្រះករុណាទេដែលមានព្រះបញ្ញាញាណ ប្រកបទៅដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ អាចដោះស្រាយបាន ក្នុងព្រះឋានៈ ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនិងការប្រព្រឹត្តទៅ នៃអំណាចសាធារណៈឱ្យមានទៀងទាត់*" ។

លោកសម *រង្ស៊ី* បានរៀបរាប់ទូលថ្វាយសម្ដេចឪ យ៉ាងដូច្នេះទៀតថា "*អាស្រ័យដូចបានទូលថ្វាយខាងលើទូលព្រះបង្គំជាខ្ញុំនិងបេក្ខជនជាប់ឆ្នោតទាំងអស់ មកពីគណបក្សសមរង្ស៊ី ត្រៀមខ្លួនជានិច្ច ដើម្បីក្រាបថ្វាយបង្គំទូលព្រះរាជតំរិះរបស់ព្រះករុណា ជាអម្ចាស់គ្រប់ពេលវេលា ក្នុងស្មារតីការពារបូរណភាពទឹកដី ប្រទេសកម្ពុជា បង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងឯកភាពជាតិ លើជំហរស្នេហាជាតិ និងប្រជាធិបតេយ្យសេរីពហុបក្ស*" ។

ជាចុងបញ្ចប់នៃលិខិត ប្រធានគណបក្សប្រឆាំង លោក*សម រង្ស៊ី*បានទូលថ្វាយសម្ដេចឪ ព្រះ*នរោត្ដម សីហនុ* ទៀតថា "*ទូលព្រះបង្គំ សូមបួងសួងដល់គុណបុណ្យ ព្រះរតនត្រ័យ វត្ថុសក្ដិសិទ្ធិក្នុងលោក ទេវតាថែរក្សា ព្រះមហាស្វេត្រឆ័ត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ សូមតាមជួយប្រោះព្រំ ថែរក្សាព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងនិងសម្ដេចព្រះវររាជបិតា ព្រមទាំងសម្ដេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សាដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ជាដរាបតរៀងទៅ*" ។

អ្នកច្បាប់ជាន់ខ្ពស់ខ្មែរ បាននិយាយថាករណីទំនាស់ព្រំដែនខ្មែរជាមួយសៀម ដ៏តឹងតែងនេះផ្ដើមចេញពីភាគីកម្ពុជាស្នើយោបល់ភាគីសៀម ឱ្យដាក់ប្រាសាទព្រះវិហារ ជាបេតិកភ័ណ្ឌពិភពលោក ។ អ្នកច្បាប់រូបនោះបាននិយាយថា តុលាការក្រុងឡាអេ បានកាត់ក្ដីឱ្យកម្ពុជាឈ្នះសៀម តាំងពីថ្ងៃទី១៥មិថុនា ១៩៦២ហើយ នៅក្រោមស្នាព្រះហស្ថ របស់អង្គសម្ដេចឪ ។ ចុះហេតុអ្វីបានជារដ្ឋាភិបាលលោក*ហ៊ុនសែន*ទៅសុំយោបល់ពីសៀម ។

ប្រភពគួរឱ្យជឿ ពីគណៈរដ្ឋមន្ត្រីបានឱ្យដឹងថា មន្ត្រីរាជរដ្ឋាភិបាល អាចពាក់ព័ន្ធនឹងអោយក្រុមហ៊ុន របស់លោក*ថាក់ស៊ីន* អតីនាយករដ្ឋមន្ត្រីសៀម ត្រូវគេទម្លាក់ពីអំណាច ឈ្មោះថាក្រុមហ៊ុនស៊ីណាវ៉ាត្រារកស៊ីរួមគ្នាជាមួយមន្ត្រីពុករលួយខ្មែរ ។ ប្រភពមិនផ្លូវការ បានឱ្យដឹងទៀតថា ការព្រមព្រៀងរវាងមន្ត្រីពុករលួយខ្មែរ ជាមួយនឹងតំណាងក្រុមហ៊ុននោះ អាចប្រគល់ដីខ្មែរ នៅតាមព្រំដែនខ្លះផង ក្រោមរូបភាពតំបន់ស តំបន់មានជម្លោះ ដែលបណ្ដាប្រទេសក្នុងពិភពលោក គ្មានទេតំបន់ត្រួតស៊ីគ្នានេះ ។ ម៉្យាងតំបន់សរវាងខ្មែរជាមួយសៀមភាច្រើន ជាតំបន់ដែលសំបូរទៅដោយរ៉ែមានតម្លៃ ដូចជាប្រេងនិងតំបន់ព្រំដែនខាងលិចដែលសំបូរប្រាសាទនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកជំនាញសេដ្ឋកិច្ច និងអ្នកជំនាញព្រំដែន បានអោយដឹងថាដោយសារតែភាពលាក់បាំងរបស់មន្ត្រីពុករលួយខ្មែរ ករណីជាតិធំៗនេះហើយ បានជាពួកចោរសៀមព្រហើន ដោយមិនខ្លាចឈ្លានពាន ។ ជាងនេះទៅទៀតនោះភាគីកម្ពុជាមិនហ៊ានប្ដឹងចោរសៀម ទៅអង្គការសហប្រជាជាតិទៀត បើទោះបីជាគេឈ្លានពានយ៉ាងកំរោលនៅកន្លែងខ្លះក៏ដោយដែលការមិនហ៊ានប្ដឹងនេះ ទំនងជាមន្ត្រីពុករលួយខ្មែរ ត្រូវថ្នាំពុលចោរសៀម(ដុល្លារ) ក៏អាចថាបានដែរ ។

ទោះបីជាសៀម ឈ្លានពានទន្ទ្រានបូរណភាពទឹកដី មើលងាយខ្មែរយ៉ាងណាក៏ដោយ ក៏លោក*ហ៊ុន សែន* បុរសខ្លាំងនៃកម្ពុជាមិនហ៊ានដែរ បានត្រឹមតែនិយាយថាអត់ធ្មត់ ។ តែបើជាមួយខ្មែរគ្នាឯងវិញ លោក *ហ៊ុន សែន* មិនអត់ធ្មត់គេ គឺច្បាស់ជាឈាមហូរ ក្រាលព្រះធរណីជាមិនខាន បើសិនជាខ្មែរណា ធ្វើឱ្យលោក*ហ៊ុន សែន* បាក់មុខ ដូចជាទាហានឈុតខ្មៅសៀមឈ្លានពាន នៅតាមព្រំដែនសព្វថ្ងៃនេះ ។

អ្នកវិភាគនិយាយថាមេដឹកនាំខ្មែរឈ្មោះ*ហ៊ុន សែន* សព្វថ្ងៃមានភាពលេចធ្លោពីរ នៅចុងអាណត្តិទី៣នេះ គឺបើកដៃឱ្យចោរសៀម ឈ្លានពានទឹកដីនៅតាមព្រំដែន យ៉ាងពពាក់ពពូន និងភាពល្បីល្បាញមួយទៀតនោះ គឺលុបឈ្មោះខ្មែរគ្នាឯងមិនឱ្យបោះឆ្នោតបាន និងបើកដៃអោយយួន បោះឆ្នោតសំរេចជោគវាសនាខ្មែរ តាមអំពើចិត្ត ។ ដោយសារតែការអសមត្ថភាពនិងមិនគិតពីជាតិនេះហើយ បានជាបរទេស ជាពិសេសសៀម ឈ្លានពានយ៉ាងកំរោលនៅតាមព្រំដែន ។

ស្ថិតនៅចំពោះមុខ នៃស្ថានភាពគ្រោះអាសន្នដល់ប្រទេសជាតិនេះហើយ បានជាលោក*សមរង្ស៊ី*ប្រធានគណបក្សសមរង្ស៊ី មានជំនឿតែលើសម្ដេចឪមួយអង្គប៉ុណ្ណោះដែលអាចដោះស្រាយបញ្ហាព្រំដែន ជាមួយចោរសៀម និងទម្លុះទម្លាយភាពជាប់គាំងនយោបាយ នៅកម្ពុជាបាន និងជាពិសេសនោះគឺអាចលើកមុខមាត់កម្ពុជានៅលើឆាកអន្តរជាតិព្រមតាំងស្ដារជីវភាពប្រជាពលរដ្ឋដែលកំពុងក្រីក្រឱ្យល្អប្រសើរបាន ៕

**តមកពីទំព័រ១ ៩**

ដំណើរការយ៉ាងគគ្រឹកគគ្រេងដដែលទេ។

គេបានបង្ហើបឱ្យយើងដឹងទៀតថា ទោះបីជា "*ខ្មែរម្ចាស់ស្រុក*" វាយបុកក្លឹបល្បែងស៊ីសងគ្រប់ប្រភេទរបស់លោក *រស់ ដៀវ* នេះខ្លាំងជាងរន្ទះក៏ដោយ ក៏ក្លឹបមួយនេះមិនរលាយរលត់ដែរ ព្រោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅក្រុងព្រះសីហនុសុទ្ធតែបានទទួល "*ទឹកតែ*" ពីលោក *រស់ ដៀវ* គ្រប់ៗគ្នា។

គេថា បើខុសពីខ្សែលោក *រស់ ដៀវ* នេះ កុំសង្ឃឹមថា បើកក្លឹបលេងល្បែងស៊ីសងខុសច្បាប់បានឱ្យសោះទោះជាពាក់ស្បែកទាហាន ឬពាក់ស្បែកប៉ូលិសក៏ដោយក៏គេចមិនផុតពីកណ្តាប់ដៃដែករបស់ប៉េអឹម *អ៊ុក អឿន* ដែរ។

ម្យ៉ាងទៀតលោកស្នងការប៉ូលិសក្រុងព្រះសីហនុក៏មិនហ៊ាន "*ក្អក*" ជាមួយក្លឹបល្បែងលោក *រស់ ដៀវ* នោះទេ ព្រោះបើគាត់ហ៊ាន "*ក្អក*" តែមួយឃ្មូសប្រាកដជាមានភ្លើងក្រហមពីចៅហ្វាយក្រុងព្រះសីហនុឈ្មោះ *ស្បោង សារ៉ាត* ភ្លាម។

ឥឡូវនេះអ្នកដែលនៅពីក្រោយខ្នងក្លឹបល្បែងស៊ីសងរបស់លោក *រស់ ដៀវ* គឺជាមេទាហាននិងប៉េអឹមនៅក្រុងព្រះសីហនុតែម្តង ដែលគួរតែលោកឧត្តមសេនីយ៍ឯក *សៅ សុខា* ជ្រាបជាព័ត៌មាន ហើយត្រូវតែមានវិធានការកំចាត់កំចាយតាមគោលការណ៍ច្បាប់យ៉ាងបន្ទាន់បំផុត ទើបជាការប្រសើរ។

ប៉ុន្តែមានសេចក្តីរាយការណ៍មួយបានបង្ហើបថា ឱ្យលោក *សៅ សុខា* ចុះទៅបង្ក្រាបក្លឹបល្បែងស៊ីសងលោក *រស់ ដៀវ* យ៉ាងដូចម្តេចបាន បើលោក *អ៊ុកអឿន*មេរងប៉េអឹមក្រុងព្រះសីហនុឈរជើងនៅទីនោះហើយនោះ ដែលយ៉ាងហោចណាស់ក៏លោក *អ៊ុក អឿន* ត្រូវផ្តល់ជាសគុណជូនថ្នាក់លើដែរ។

នៅមានសេចក្តីរាយការណ៍ដាច់ដោយឡែកមួយទៀតបានអះអាងថា មេប៉េអឹមលើផ្ទៃប្រទេសឈ្មោះ *សៅ សុខា* ម្នាក់នេះមិនយកមុខតំណែងរបស់ខ្លួនទៅប្រឡាក់ប្រឡូសនឹងក្លឹបល្បែងលោក *រស់ ដៀវ* នោះទេ។ហើយគេសង្ឃឹមថា ប្រសិនបើលោក *សៅ សុខា* ដឹងថាមានកូនចៅទៅកាងការពារក្លឹបល្បែងស៊ីសងខុសច្បាប់វិញនោះ លោកនឹងចាត់ការដោយគ្មានបន្ធូរដៃឡើយ។

យោងតាមមតិនេះហើយទើបប្រជាពលរដ្ឋនៅក្រុងព្រះសីហនុរង់ចាំមើលស្នាដៃលោក *សៅ សុខា* នោះ តើហ៊ានទៅបង្ក្រាបក្លឹបល្បែងស៊ីសងរបស់លោក *រស់ ដៀវ* ដែរ ឬក៏អត់?

គួររំលឹកថា ក្លឹបល្បែងស៊ីសងលុយដុំៗចាញ់ឈ្នះរាប់ពាន់រាប់ម៉ឺនដុល្លារ មួយកន្លែងស្ថិតនៅភូមិ២ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កំពុងបើកលេងយ៉ាងអនាធិបតេយ្យបំផុតតាំងពីយូរណាស់មកហើយដោយគ្មានអាជ្ញាធរមានសមត្ថកិច្ចណាហ៊ានចាត់ការក្លឹបល្បែងស៊ីសងខុសច្បាប់នោះឡើយ។

ប្រភពព័ត៌មានពីក្រុងព្រះសីហនុបានឱ្យដឹងថា ថៅកែក្លឹបល្បែងស៊ីសងនេះជាទាហានមានស័ក្តិខ្ពស់គួរសមដែរឈ្មោះ*រស់ ដៀវ* ដែលជាអ្នកធ្លាប់បើកលេងល្បែងស៊ីសងខុសច្បាប់ជើងយូរម្នាក់នៅក្រុងព្រះសីហនុ។

មិនតែប៉ុណ្ណោះប្រភពបានបង្ហើបបន្ថែមទៀតថា ប្រសិនបើគ្មានលោក *អ៊ុក អឿន* ជាមេបញ្ជាការរងប៉េអឹមក្រុងព្រះសីហនុជាអ្នកកាងការពារក្លឹបល្បែងស៊ីសងគ្រប់ប្រភេទនេះទេ គឺឈ្មោះ *រស់ ដៀវ* មិនអាចត្រូវប៉ាន់គ្រប់ទឹករហូតមកដល់សព្វថ្ងៃនេះឡើយ។

ប្រភពបានឱ្យយើងដឹងទៀតថា កាលពីលោក *ស្បោង សារ៉ាត*មិនទាន់បានឡើងបុណ្យជាចៅហ្វាយក្រុងព្រះសីហនុនោះ គឺក្លឹបរបស់លោក*រស់ ដៀវ* នេះជួនបើកលេង ជួនបិទព្រោះគេហ៊ានទៅតាមកាលៈទេសៈដែលផ្តល់ឱ្យ។

ប៉ុន្តែបន្ទាប់ពីលោក *ស្បោង សារ៉ាត* ឡើងធ្វើជាចៅហ្វាយក្រុងព្រះសីហនុយ៉ាងពេញមុខមក គឺក្លឹបល្បែងស៊ីសងមួយកន្លែងនេះត្រូវបានបើកលេងទាំងយប់ ទាំងថ្ងៃ ដោយសេរីតែម្តង ដែលស្មើនឹងមានន័យថាក្លឹបល្បែងស៊ីសងលោក *រស់ ដៀវ* បើកលេងយ៉ាងគគ្រឹកគគ្រេងដើម្បីអបអរសាទរជូនជាកាដូឱ្យលោក*ស្បោងសារ៉ាត*ឆ្អែតដល់កតែម្តង។

គេបានឱ្យយើងដឹងច្បាស់ថា នៅក្នុងក្លឹបល្បែងស៊ីសងរបស់លោក *រស់ ដៀវ* ដែលការពារដោយលោក*អ៊ុក អឿន* មេបញ្ជាការរងប៉េអឹមក្រុងព្រះសីហនុនោះរួមមានល្បែងយូគី, អាប៉ោង, បៀ, ជល់មាន់ និង ហ្គេមម៉ាស៊ីន។

ក្នុងចំណោមអ្នកដែលទៅលេងល្បែងស៊ីសងនៅក្លឹបលោក *រស់ ដៀវ* នោះ គឺកម្រមានអ្នកឈ្នះណាស់ព្រោះមេល្បែងមួយវង់ៗសុទ្ធតែបង្កប់ល្បិចស៊ីលើអ្នកលេងទាំងអស់។

ដូច្នេះមានអ្នកចាញ់អស់លុយរាប់ពាន់ រាប់ម៉ឺនដុល្លារខ្លះចាញ់ដល់ថ្នាក់រត់ចោលផ្ទះសម្បែងដោយសារជំពាក់បំណុលគេជុំទិសថែមទៀតផង។ ទន្ទឹមនេះបើនិយាយពីចោរលួច, ចោរប្លន់នៅក្រុងព្រះសីហនុវិញ ក៏កើតមានជារៀងរាល់ថ្ងៃដែរ ដែលចោរខ្លះនៅពេលលួច-ប្លន់បានសម្រេចហើយក៏យកទៅបង្គ្រប់ផុកនៅក្លឹបល្បែងស៊ីសងរបស់លោក *រស់ ដៀវ* ជាបន្តទៀត។

ប្រជាពលរដ្ឋនៅក្រុងព្រះសីហនុបានសម្តែងនូវការកង្វល់ថាការបើកឱ្យមានល្បែងស៊ីសងខុសច្បាប់បែបនេះ ដូចធ្វើឱ្យមានអសន្តិសុខសង្គមកើតឡើងជាប្រចាំតែម្តងដែលគួរតែអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រិះរិះពិចារណាជាបន្ទាន់ផង ដើម្បីកុំឱ្យគេរិះគន់ថា "*នាំគ្នាត្រូវរ៉ូវជាមួយលោក រស់ ដៀវបើកក្លឹបល្បែងស៊ីសងអនាធិបតេយ្យបង្កឱ្យមានអសន្តិសុខកើតឡើងពេញក្រុងព្រះសីហនុ*" នោះ។

តាមពិតទៅប្រជាពលរដ្ឋនៅក្រុងព្រះសីហនុជឿជាក់លើស្នាដៃ និងភាពឈ្លាសវៃរបស់លោកឧត្តមសេនីយ៍ឯក *សៅ សុខា* មេបញ្ជាការប៉េអឹមលើផ្ទៃប្រទេសខ្លាំងណាស់។

ប៉ុន្តែប្រសិនបើលោក *សៅ សុខា* មិនអាចបំបែកសំបុកបនល្បែងស៊ីសងខុសច្បាប់របស់លោក *រស់ ដៀវ* ដែលមានទីតាំងនៅភូមិ២ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុបានទេ គឺប្រជាពលរដ្ឋនឹងនាំគ្នាដាក់ការសង្ស័យលើលោកថាជាអ្នកមានចំណែកសើមមាត់នៅក្នុងក្លឹបល្បែងខុសច្បាប់នេះជាមិនខាន៕

**តមកពីទំព័រ២ គ**

ដ៏ឆ្នើមអង្គនេះគ្មានចំណុចណាមួយអាចនិយាយបានថាជាមនុស្សស្លូតត្រង់នោះទេ ព្រោះទ្រង់ធ្លាប់បោកប្រាស់លោក *សម រង្ស៊ី* រហូតដល់ថ្នាក់លោក *សម រង្ស៊ី* ហៅទ្រង់ *រណឫទ្ធិ* ថាជាមនុស្សកែលែងឡើងទៅហើយ។

ឥឡូវបើយោងតាមការផ្សាយព័ត៌មានរបស់កាសែតក្នុងស្រុកមួយដែលស្និទ្ធនឹងទ្រង់ *រណឫទ្ធិ*ដ៏មហាកំពូលល្បិចនេះបានឱ្យដឹងថា ទ្រង់នឹងយាងពីប្រទេសម៉ាឡេស៊ីចុះមកលេងខេត្តសៀមរាបនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៨ ខាងមុខនេះ ហើយពោលគឺបន្ទាប់ពីការកោះប្រជុំសភាលើកដំបូង, ការធ្វើសច្ចាប្រណិធាន និងការបោះឆ្នោតជាកញ្ចប់បង្កើតមេដឹកនាំសភា និងរដ្ឋាភិបាលក្នុងពេលតែមួយចប់សព្វគ្រប់ទើបព្រះរាជបុត្រកំពូលបោកអង្គនេះហ៊ានយាងចូលស្រុកខ្មែរ។

គេថា រហូតមកដល់ពេលនេះ ទ្រង់ *រណឫទ្ធិ* នៅតែមានទោសជាប់ខ្លួននៅឡើយទេ តែបើទ្រង់ចង់យាងមកស្រុកខ្មែរក្នុងថ្ងៃនេះតែម្តង ក៏ទ្រង់គ្មានបញ្ហាអ្វីដែរ ព្រោះទ្រង់បានត្រូវរ៉ូវជាមួយលោក *ហ៊ុន សែន* រួចហើយនោះ ដែលពុំមានអំណាចសាលក្រមតុលាការថ្នាក់ណាមួយអាចហ៊ានប៉ះពាល់ដល់ព្រះកាយទ្រង់ *រណឫទ្ធិ* ឡើយ ប្រសិនបើគ្មានបញ្ជាពីលោក *ហ៊ុន សែន* ទេនោះ។

មជ្ឈដ្ឋានជាទូទៅបានវាយតម្លៃរួចជាស្រេចថា ការទាស់ទែងខ្វែងគំនិតគ្នារវាងទ្រង់ *រណឫទ្ធិ* និងលោក *ហ៊ុន សែន* សុទ្ធតែជាឆាកល្ខោនទាំងអស់។ ហើយសូម្បីតែការត្រូវរ៉ូវគ្នាថ្មីៗនេះទៀតសោត ក៏ជាឆាកល្ខោនគួរឱ្យអស់សំណើចដែរ ពោលគឺឆាកល្ខោនបែបនេះប្រជាពលរដ្ឋខ្មែរមើលឡើងជ្រិញទៅហើយ។

ឥឡូវនេះប្រជាពលរដ្ឋខ្មែរដាក់សំណួរទុកជាមុនថា តើដល់ឆ្នាំ២០១៣ ទ្រង់ *រណឫទ្ធិ* និងលោក *ហ៊ុន សែន* មានបង្កើតសេណារីយោ "*សាប់គ្នា*" ឱ្យបែកទឹកបែកដីហុយសំពោងទៀតទេ? ប្រសិនបើមានទៀតសូមជួយជូនដំណឹងឱ្យប្រជាពលរដ្ឋខ្មែរបានដឹងជាមុនផង ហេ! ហេ! ៕

**តមកពីទំព័រ៤ ន**

មានការអនុវត្តន៍ផែនការកែទម្រង់កម្លាំងប្រដាប់អាវុធក្រោមជំនួយឧបត្ថម្ភរបស់ធនាគារម្ចាស់ជំនួយហិរញ្ញវត្ថុនេះ។

លោក *សុន ឆ័យ* បានថ្លែងយ៉ាងនេះថាទាក់ទងនឹងគម្រោងកាត់កងទ័ពក្នុងឆ្នាំ២០០១នោះ ឯកសារ និងរបាយការណ៍របស់ធនាគារពិភពលោកបង្ហាញឱ្យឃើញថា នៅក្នុងបញ្ជីរបស់រដ្ឋាភិបាល ប្រទេសកម្ពុជាមានកងទ័ពចំនួន១៤ម៉ឺននាក់។ប៉ុន្តែចំនួននោះមានតែនៅក្នុងបញ្ជីប៉ុណ្ណោះ។

ពួកអ្នកសង្កេតការណ៍និយាយថា បើនេះវាជាករណីពិតមែននោះ វាមានន័យថាកម្លាំងសមត្ថភាពនៃកកងទ័ពកម្ពុជានៅក្រោមការដឹកនាំរបស់រដ្ឋាភិបាលគណបក្សប្រជាជនមិនមានទំហំគ្រប់គ្រាន់ឱ្យប្រទេសជិតខាងកោតញញើតខ្មែរនោះទេ។ ហើយនេះក៏ជាកង្វះខាតនៃការដឹកនាំរបស់រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ខ្លួនឯង។

នៅក្នុងស្ថានភាពដែលកងទ័ពមានកាតព្វកិច្ចការពារបូរណភាពទឹកដីរបស់ប្រទេសជាតិខ្វះខាតជីវភាព ទាំងមានបរិក្ខាចាស់មិនទាន់សម័យប្រឈមមុខនឹងកងទ័ពឈ្លានពានរបស់សៀមប្រដាប់ដោយអាវុធទំនើបគួបផ្សំនឹងមានកម្លាំងពលរឹងមាំនោះ វាគឺជាការបញ្ជាក់ថាប្រទេសសៀមមិនកោតញញើតនឹងការគម្រាមកំហែង និងបន្តឈ្លានពានកាន់កាប់ទឹកដីខ្មែរនៅតំបន់ផ្សេងៗនោះឡើយ។

ម្យ៉ាងទៀតក្នុងស្ថានភាពដែលកងកម្លាំងទ័ពរបស់ប្រទេសមានលក្ខណៈបែបនេះ គេបែរជាសង្កេតឃើញថា នាយករដ្ឋមន្ត្រី *ហ៊ុន សែន* អនុប្រធានគណបក្សប្រជាជនកាន់អំណាចបានបង្កើតកងទាហានអង្គរក្សដល់ទៅជិតជាង៦ពាន់នាក់ប្រដាប់ដោយអាវុធទំនើប និងឯកសណ្ឋានប្រណីតៗ សម្រាប់តែហែហមគាត់ទៅតាមពិធីនានា ជាជាងការបញ្ជូនកម្លាំងអស់នេះទៅអោយតទល់នឹងកងទ័ពឈ្លានពានរបស់សៀមនោះ។

លោក *សុន ឆ័យ* ក៏បានថ្លែងរិះគន់ផងដែរអំពីរបស់ដែលហៅថា នយោបាយនៃការកាត់បន្ថយអាវុធអនុវត្តដោយរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ដោយការប្រមូលអាវុធយកមកបំផ្លាញចោល។ លោកបានហៅថា នោះជាសញ្ញាមិនល្អមួយប្រាប់អំពីចំណុចខ្សោយរបស់កម្ពុជាចំពោះមុខខ្សែភ្នែករបស់ប្រទេសជិតខាងដែលបង្កប់ដោយមហិច្ឆតា។តាមការថ្លែងរបស់លោកនោះ រដ្ឋាភិបាលគួរតែគិតគូរឱ្យបានច្បាស់អំពីការគ្រប់គ្រងអាវុធបរិក្ខាឧបត្ថម្ភដល់កងកម្លាំងទ័ពរួមទាំងស្បៀងអាហារគ្រប់គ្រាន់ដើម្បីឱ្យក្លាយជាកងកម្លាំងរបស់ប្រទេសជាតិ។

ចំណុចមួយទៀតដែលជារឿងប៉ះពាល់ដល់សតិអារម្មណ៍របស់កងទ័ពខ្មែរដែលកំពុងឈរជើងនៅតាមតំបន់ជាយដែននោះ គឺគ្រួសាររបស់យោធានៅឯសហគមន៍មូលដ្ឋានឯណេះបែរជារងការធ្វើទុក្ខបុកម្នេញដោយត្រូវអាជ្ញាធរដែនដីរឹបអូសយកដីធ្លីនិងដុតផ្ទះសម្បែង។

ជាក់ស្តែងនោះលោក *សុន ឆ័យ* បានលើកនិយាយអំពីការដែលភរិយារបស់កងទាហានខ្មែរដែលកំពុងបំពេញបេសកកម្មតទល់ជាមួយនឹងទាហានសៀមឈ្លានពានបែរជារងគ្រោះដោយការធ្វើបាបពីសំណាក់អាជ្ញាធរដែនដីធ្វើការរុះរើផ្ទះសម្បែងនិងដុតបំផ្លាញចោល ដែលនេះប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍របស់កងកម្លាំងដែលកំពុងបំពេញកាតព្វកិច្ចតទល់នឹងការទន្ទ្រានរបស់ទាហានប្រទេសជិតខាង។

តើសកម្មភាពនៃការប្រឈមមុខដាក់គ្នារវាងកងទាហានខ្មែរនិងកងទាហានឈ្លានពានសៀមទៅជាឱកាសពន្លេចឱ្យឃើញនូវស្ថានភាពខ្សោយនៃកងទ័ពខ្មែរនៅក្រោមការដឹកនាំរបស់រដ្ឋាភិបាលគណបក្សប្រជាជនឬ ? អ្វីៗតាមការអធិប្បាយរបស់លោក *សុន ឆ័យ* ដកស្រង់ពីប្រភពសារព័ត៌មានបរទេសនោះបញ្ហាស្មុគស្មាញនៃកងទាហានសៀមឈ្លានពានតាមតំបន់ព្រំដែន មួយផ្នែកគឺដោយសារទាហានសៀមមើលឃើញកម្លាំងខ្សោយរបស់ទាហានខ្មែរហើយម្យ៉ាងទៀតនោះក៏ព្រោះតែអ្វីៗដែលអាចជាកិច្ចសន្យាសម្ងាត់ដែល *ហ៊ុន សែន* បានចុះហត្ថលេខាជាសម្ងាត់ជាមួយអតីតនាយករដ្ឋមន្ត្រីសៀម *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* តាំងពីឆ្នាំ២០០០មកនោះ៕

**តមកពីទំព័រ១ ឃ**

ផ្ទៃក្នុងនោះ ផ្តើមចេញពីអ្នកតវ៉ា ដែលប្រើយីហោស្តេចខ្លួនប្រឆាំងនឹងគណបក្សដែលកាន់អំណាច ។

ប្រជាពលរដ្ឋសៀម និងអ្នកជំនួញធម្មតា ដែលប្រកបមុខរបររកស៊ី នៅផ្សាររ៉ុងក្លឿនៅជាប់ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យបានត្អូញត្អែរថាព្រះមហាក្សត្រព្រះបាទ *ភូមិពល អតុលយ៉ាដេត* នាពេលចុងក្រោយនេះ ហាក់ដូចជាសព្វព្រះទ័យ អោយប្រទេសជាតិ ជួបប្រទះនូវបញ្ហាធ្ងន់ធ្ងរ ហើយអ្វីដែលព្រះអង្គកំពុងស្រមើស្រមៃនោះ មិនត្រឹមត្រូវទាល់តែសោះ ។

ទោះយ៉ាងណា ប្រជាពលរដ្ឋសៀមដែលហ៊ាននិយាយប្រាប់អ្នករកស៊ីខ្មែរ នៅប៉ោយប៉ែតប៉ុន្មានថ្ងៃនេះ មិនហ៊ានបង្ហាញឈ្មោះ និងអត្តសញ្ញាណទេ ។ ដូចគ្នានេះដែរ ពលរដ្ឋសៀមខ្លះទៀត ដែលឆ្លងដែនចូលស្រុកខ្មែរ មកលេងល្បែងកាស៊ីណូនៅប៉ោយប៉ែត ក៏បាននិយាយស្រដៀងគ្នាដែរថា មានប្រជាពលរដ្ឋសៀមច្រើនជាងមុន នាំគ្នានិយាយរិះគន់ស្តេចរបស់ខ្លួនដែលពួកគេ បានគោរពខ្លាំងនាពេលមុន ។ ពលរដ្ឋសៀមរូបនោះ បានលើកឡើងអំពីប្រជាពលរដ្ឋសៀមខ្លះទៀត ដែលហ៊ាននិយាយដូចគ្នាថាប្រហែលលោក *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* ដឹកនាំប្រទេស រីកចំរើន ប្រជាពលរដ្ឋស្រឡាញ់ច្រើន បែរជាមានរដ្ឋប្រហារយោធា កាលពីខែកញ្ញា ឆ្នាំ២០០៦ ។

មានពលរដ្ឋសៀមខ្លះ ហ៊ាននិយាយមើលស្រាល ដល់ស្តេចរបស់ខ្លួនថា បើប្រជាពលរដ្ឋស្រឡាញ់ស្តេចដូចមុន នឹងមិនបោះឆ្នោត ឱ្យគណបក្សរបស់លោក *សាម៉ាក់ ស៊ុនដារ៉ាវេត* ដែលគេដឹងឮថា ជាគណបក្សដែលបង្កើតឡើង ដោយលោក *ថាក់ស៊ីន* នោះទេ ។

បងប្អូនខ្មែរ ដែលរស់នៅឃុំប៉ោយប៉ែតបាននិយាយថា ពលរដ្ឋសៀម ហ៊ាននិយាយរិះគន់ស្តេចរបស់ខ្លួន នៅពេលដែលប្រទេសជាតិជួបភាពចលាចលនាពេលចុងក្រោយនេះ ដែលធ្វើឱ្យមានការបែកបាក់ ផ្ទៃក្នុងរបស់ជាតិ ពិសេសមានការធ្វើបាតុកម្មប្រឆាំងគ្នា ដែលឈានទៅដល់ការប្រើអំពើហិង្សានិងបណ្តាលឱ្យស្លាប់ និងរបួសផងនោះ។ប៉ុន្តែពលរដ្ឋសៀមដែលហ៊ាននិយាយរិះគន់ស្តេចខ្លួនឯងនេះ មិនអត្ថាធិប្បាយនឹងក្រុមទាហានឃុតខ្មៅសៀម ដែលគេដឹងថា ជាកងការពារ ព្រះមហាក្សត្រសៀម ឈ្លានពានបូរណភាពទឹកដីនៅតាមព្រំប្រទល់ដែនឡើយដូចជាតំបន់នៅក្បែរប្រាសាទព្រះវិហារ ប្រាសាទតាមាន់ធំ ជប់គគីរ ជាំស្រង៉ាំ និងប្រាសាទតាក្របីនោះជាដើម ។

ពលរដ្ឋខ្មែរ ដែលជាអ្នកជំនួញខ្លះនៅឃុំប៉ោយប៉ែត មានទំនាក់ទំនង ជាមួយអ្នករកស៊ីជនជាតិសៀម ក៏បាននិយាយស្រដៀងគ្នានេះដែរពាក់ព័ន្ធនឹងព្រះមហាក្សត្ររបស់ខ្លួន ដែលចេះតែប្រើអារម្មណ៍ស្រមើស្រមៃ នៅពីក្រោយខ្នងនៃការបង្កើតឱ្យមានភាពវឹកវរ នៅក្នុងប្រទេស ។

បើទោះបីជា មានប្រជាពលរដ្ឋសៀម នៅតាមព្រំដែន និងនៅឯទីជនបទខ្លះ បង្ហាញអំពីភាពមិនសប្បាយចិត្ត ទៅនឹងស្តេចរបស់ខ្លួនក៏ដោយ ក៏មានបញ្ញវន្ត និងទាហានសៀមភាគច្រើនពិសេសទាហានឃុតខ្មៅនៅតែគោរពនិងស្មោះស្ម័គ្រនឹងស្តេចរបស់ខ្លួនជានិច្ច ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**
មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។
-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម
ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**
**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News
ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
**Tel: 012 850 690 / 017 360 678 , Fax: 023 987 411**

**តមកពីទំព័រ១ ម**

នេះដើម្បីតថ្លៃ ចង់បានតំណែងជាប្រធានគណៈកម្មការ ។

ការចោទប្រកាន់ដោយគ្មានមូលដ្ឋាននេះ បានធ្វើឱ្យមេដឹកនាំគណបក្សសម រង្ស៊ី អះអាងថា ពុំមែនជាការពិតទេ ហើយមកដល់នឹងពេលនេះគណបក្សសម រង្ស៊ី អត់សុំតំណែងស្អីពីគណបក្សប្រជាជនឡើយក្រៅតែពីការ ចង់អោយប្រជាពលរដ្ឋមានសេចក្តីសុខសាន្ត មានជីវភាពធូរធារ និងគ្មានអ្នករំលោភបំពាន ប្លន់យកដីធ្លីតែប៉ុណ្ណោះ ។

លោក*សម រង្ស៊ី*ប្រធានគណបក្សសម រង្ស៊ី បានថ្លែងនៅក្នុងកម្មវិធីភ្លើងទៀន តាមវិទ្យុសំបុកឃ្មុំ FM-105 MHz កាលពីថ្ងៃព្រហស្បតិ៍បញ្ជាក់អំពីជំហររបស់សមាជិកសភា គណបក្សសម រង្ស៊ី មិនព្រមចូលប្រជុំនៅថ្ងៃដំបូង និងស្បថជាមួយនឹងសភាចោរ សភាយួន និងសភាខ្មោចថា មកដល់ពេលនេះគណបក្សសម រង្ស៊ី អត់ចង់បានអ្វីពីលោក*ហ៊ុន សែន* និងគណបក្សប្រជាជនទាល់តែសោះ ហើយ សមាជិកសភា គណបក្សសម រង្ស៊ី ក៏ដូចជាសមាជិក សមាជិកា ព្រមទាំងថ្នាក់ដឹកនាំគណបក្សសម រង្ស៊ី មិនលក់ឧត្តមគតិ ដើម្បីអំណាច និងផលប្រយោជន៍ផ្ទាល់ខ្លួននោះដែរ ។

លោក*សម រង្ស៊ី* បានមានប្រសាសន៍ ប្រកបដោយភាពស្វាហាប់និងអង់អាចថា មហិច្ឆតារបស់គណបក្សសម រង្ស៊ី គឺចង់ឱ្យប្រជាពលរដ្ឋមានសេចក្តីសុខសាន្ត ជីវភាពធូរធារ មិនទទួលរងនូវភាពអយុត្តិធម៌ ពីអ្នកមានអំណាច អ្នកមានប្រាក់ ប្លន់យកដីធ្លី ស្រែ ចំការ ចង់ឱ្យទំនិញចុះថ្លៃ ការពារបូរណភាពទឹកដី មិនអោយបរទេសមើលងាយ រំលោភបំពាន ។

លោក*សម រង្ស៊ី* បានមានប្រសាសន៍ ប្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ថាកុំអស់សង្ឃឹមរឹងប៉ឹងឡើង, ហើយនៅកម្ពុជាមិនមែនមានតែ អ្នកលក់ឧត្តមគតិអ្នកគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនទាំងអស់គ្នាទេ ។ ប្រធាន គណបក្សប្រឆាំងរូបនេះបានបញ្ជាក់ថា ការដែលគណបក្សសម រង្ស៊ី មិនចូលរួមប្រជុំសភានៅថ្ងៃដំបូងនិងស្បថចូលកាន់តំណែង ជាមួយសភាចោរ សភាយួន និងសភាខ្មោចនេះគឺជាការគោរពឆន្ទៈ របស់ប្រជាពលរដ្ឋជាងមួយលាននាក់ដែលបានបោះឆ្នោត ជូនគណបក្សសម រង្ស៊ី និងរាប់លាននាក់ទៀត ដែលគេលុបឈ្មោះ និងបង្កភាពស្មុគស្មាញ មិនអោយបោះឆ្នោតបាន ។

លោក*ជាម យៀប*សមាជិកសភា និងជាមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន បានថ្លែងកាលពីពេលថ្មីៗនេះថា គណបក្សសម រង្ស៊ី ធ្វើពហិការមិនចូលរួមប្រជុំសភានៅថ្ងៃដំបូងនេះ គឺដើម្បីតថ្លៃចង់បានតំណែងជាប្រធានគណៈកម្មការសភា ។ ប៉ុន្តែអ្នកតំណាងរាស្ត្រ*សុន ឆ័យ* និងជាអ្នកនាំពាក្យគណបក្សសម រង្ស៊ី បានអះអាងថា រហូតមកដល់ពេលនេះ គណបក្សសម រង្ស៊ី អត់បានសុំអ្វី ពីគណបក្សប្រជាជនទាល់តែសោះ ។

ចំពោះសម្តីលោក*ហ៊ុន សែន* ដែលថា នឹងគ្រប់គ្រងអំណាចនៅស្ថាប័នរដ្ឋសភាទាំងអស់ គឺមិនប្រគល់ ប្រធានគណៈកម្មការខ្លះអោយគណបក្សប្រឆាំងខ្លះទេ វាច្បាស់ណាស់ថាកម្ពុជាធ្លាក់ចូល ទៅក្នុងរបបផ្តាច់ការហើយ ។ លោក*សុន ឆ័យ* បានថ្លែងថា "*បើបែបនេះ វាធ្វើឱ្យប្រទេសកម្ពុជាយើងនឹងវិលត្រឡប់ទៅរកភាពផ្តាច់ការ មិនមែនជា របបប្រជាធិបតេយ្យ, ហើយក៏ជារបបមួយដែលគណបក្សប្រជាជនខ្លួនឯងមិនគាំទ្រដែរ...។ គណបក្សមួយ ដែលទទួលបានការគាំទ្រ ពីប្រជាពលរដ្ឋច្រើនជាងគេនៅក្នុងប្រទេស ត្រូវចេះបង្ហាញលក្ខណៈមួយអំពីប្រជាធិបតេយ្យឱ្យប្រជាពលរដ្ឋឃើញឱ្យចេះនិយាយគ្នា ដើម្បីធ្វើយ៉ាងម៉េចអោយការបង្កើតសភាថ្មីរដ្ឋាភិបាលថ្មីនេះ ឱ្យវាទៅដោយមានការអស់ចិត្តទាំងអស់គ្នា, ហើយប្រជាពលរដ្ឋ ក៏មានការសង្ឃឹមនៅក្នុងជីវិតរស់នៅដែរ*" ។

លោក*សុន ឆ័យ* បានបន្តថា គណបក្សសម រង្ស៊ី ប្រឆាំងដាច់ខាត នឹងគណបក្សកាន់អំណាច ក្នុងគោលបំណងបែបណា នាំកម្ពុជាអោយធ្លាក់ចូល ទៅក្នុងរបបផ្តាច់ការ ។ ដូច្នេះហើយបានជាគណបក្សសម រង្ស៊ីបានសំរេចចិត្តមិនចូលរួមប្រជុំសភានៅថ្ងៃដំបូងដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៤ កញ្ញានេះ ។ អ្នកតំណាងរាស្ត្រ*សុន ឆ័យ* បានឱ្យដឹងថា គណបក្សប្រជាជន កំពុងត្រូវការ គណបក្សប្រឆាំងខ្លាំងណាស់ ពីព្រោះសមាជិករាជរដ្ឋាភិបាលថ្មីនេះ មានច្រើនហើយអ្នកទាំងនោះ មិនមែនសុទ្ធតែល្អទេ ។

លោក*សុន ឆ័យ* ក៏បានឱ្យដឹងផងដែរ ចំពោះលោក*ហ៊ុន សែន* ព្រមានចង់យកកៅអីរដ្ឋសភាគណបក្សសម រង្ស៊ី ទាំង ២៦ ទៅចែកគ្នាថា សមាជិកសភាគណបក្សសម រង្ស៊ី ទាំង ២៦រូប មិនបោះបង់ចោលកៅអីរបស់ខ្លួនទេ ប៉ុន្តែក៏មិនបារម្ភនឹងការព្រមានរបស់លោក*ហ៊ុន សែន* ដែរ ។

ព័ត៌មាន ដាច់ដោយឡែកមួយទៀតដែល*ខ្មែរម្ចាស់ស្រុក* ទទួលបាន ពីមន្ត្រីព្រះបរមរាជវាំងបានអោយដឹងថា ខាងព្រះបរមរាជវាំង គ្រោងនឹងស្នើឱ្យសមាជិកសភា គណបក្សសម រង្ស៊ី ស្បថកាន់តំណែង នៅថ្ងៃទី២៤ កញ្ញា ២០០៨ នោះដែរតែធ្វើដាច់ដោយឡែកពីគ្នា ពីសមាជិកសភា គណបក្សប្រជាជន គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ។

ប្រភពដែលគួរជឿ បានឱ្យដឹងទៀតថា ខាងព្រះបរមរាជវាំង នឹងរៀបចំអោយសមាជិកសភាគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ស្បថនៅក្រោយពីបញ្ចប់ការស្បថរបស់សមាជិកសភា ពីគណបក្សប្រជាជន គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ប្រមាណជា កន្លះម៉ោងឬមួយម៉ោង។ ហើយការធ្វើបែបនេះ ត្រូវបានមន្ត្រី ព្រះបរមរាជវាំង អះអាងថា បន្ថយភាពតានតឹងនយោបាយដែលអាចនឹងឈានដល់អស្ថេរភាពសង្គម ៕

**តមកពីទំព័រ១ ក**

**ជាង៤ពាន់រៀលក្នុងមួយលីត្រ ហើយថានេះមិនមែនជាការធ្វើប្រជាភិថុតិចង់បានចំណេញនយោបាយសម្រាប់គណបក្សប្រជាជននោះទេ។**

**តើនេះជាការធ្វើនយោបាយក្នុងល្បិចប្រជាភិថុតិកេងចំណេញសម្រាប់នយោបាយនៃលោក ហ៊ុន សែន មែន ឬមិនមែននោះ មិនចាំបាច់លោក គាត ឈន់ បកស្រាយនោះទេ។ ការបកស្រាយទាំងនេះជាការទទួលស្គាល់រួចទៅហើយថា ការដែលរដ្ឋាភិបាលធ្វើជាយកចិត្តទុកដាក់ក្នុងការទម្លាក់តម្លៃប្រេង ស្របពេលដែលប្រជារាស្ត្រខ្មែរកំពុងក្តៅក្រហាយពាសពេញប្រទេស មានហេតុផលពីរយ៉ាង។ ទីមួយ គឺគណបក្សប្រជាជនខ្លាចប្រឈមនឹងកម្លាំងប្រជារាស្ត្រធ្វើការតវ៉ាដូចកើតមាននៅប្រទេសនានាដោយសារបញ្ហាទំនិញឡើងថ្លៃនាំមុខដោយប្រេងសាំង។ ទីពីរនោះគឺគណបក្សប្រជាជនចង់បង្ហាញថា ខ្លួនយកចិត្តទុកដាក់ដោះស្រាយបញ្ចុះតម្លៃប្រេង។**

**ប៉ុន្តែនេះក៏ជាការបើកបង្ហាញឱ្យប្រជារាស្ត្រដឹងឮទូទាំងប្រទេសទៅវិញថា នេះគឺជាពុតត្បុតនយោបាយរបស់គណបក្សប្រជាជន ក្រោយពីបើកដៃឱ្យឈ្មួញកើបចំណេញពីលើក្បាលរាស្ត្រអស់រាប់រយលានដុល្លារច្រើនឆ្នាំមកហើយ ក៏គណបក្សនេះធ្វើជាចិត្តល្អមកជួយឈឺឆ្អាលនឹងទុក្ខវេទនារបស់ប្រជារាស្ត្រ លើសពីនេះទៀត វារឹតតែធ្វើឱ្យប្រជារាស្ត្រដឹងយ៉ាងច្បាស់ថា ក្រុមមន្ត្រីកាន់អំណាចរបស់គណបក្សប្រជាជន ហ៊ុន សែន ធ្វើអ្វីៗដើម្បីបំរើផលប្រយោជន៍ឈ្មួញនៅត្រង់ថា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសអំពីការបញ្ចេញលុយរដ្ឋមួយឆ្នាំៗរាប់រយលានដុល្លារថាយកទៅទូទាត់តម្លៃប្រេងសាំងជួយដល់ប្រជារាស្ត្រ។**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះបានប្រកាសថា តាំងតែពីខែមករា មកដល់ពេលនេះ រដ្ឋាភិបាលបានបញ្ចេញលុយរដ្ឋចំនួន២៦៣លានដុល្លារដើម្បីអ្វីដែលគាត់ប្រើពាក្យថា ឧបត្ថម្ភស្វាត់ៗជួយប្រជារាស្ត្រកុំឱ្យប៉ះពាល់ដល់តម្លៃប្រេងឡើងថ្លៃ។ គាត់បានបន្តអធិប្បាយថា ឥឡូវមួយខែៗរដ្ឋក៏នៅបន្តឧបត្ថម្ភស្វាត់ៗដើម្បីជួយទប់ស្កាត់ផលប៉ះពាល់នៃតម្លៃប្រេងទៅលើជីវភាពរបស់ប្រជារាស្ត្រទូទៅដែរ។**

**ប៉ុន្តែប្រជារាស្ត្រខ្មែរខ្លួនឯងដឹងយ៉ាងច្បាស់ថា ពួកគាត់គឺជាអ្នករងគ្រោះមិនមែនត្រឹមតែពេលនេះ ប៉ុន្តែបានរងគ្រោះអស់រយៈពេលច្រើនឆ្នាំមកហើយ ហើយនៅតែបន្តរងគ្រោះជាបន្តទៅទៀតដោយសារតែអំពើពុករលួយ និងគំនិតឱកាសនិយមរបស់ពួកអ្នកកាន់អំណាចឃុបឃិតជាមួយឈ្មួញក្រុមហ៊ុនប្រេងធំៗកេងចំណេញលើញើសឈាមរបស់ប្រជារាស្ត្រដែលកំពុងរងគ្រោះវេទនាស្រាប់នោះ។**

**ហើយអំពីអ្វីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ ប្រកាសថា រដ្ឋាភិបាលកម្ពុជា នៃ ហ៊ុន សែន បានបញ្ចេញលុយរដ្ឋមួយខែៗ៣០លានដុល្លារឧបត្ថម្ភស្វាត់ៗទប់ស្កាត់តម្លៃប្រេងកុំឱ្យប៉ះពាល់ដល់ជីវភាពប្រជារាស្ត្រ ប្រជារាស្ត្រផ្ទាល់ទៅជាយល់ឃើញផ្ទុយពីនេះ។ ប្រជារាស្ត្រយល់ថា នោះគឺជាការបញ្ចេញលុយរដ្ឋមួយខែៗ៣០លានដុល្លារសម្រាប់ចែកគ្នាស្វាត់ៗរវាងមន្ត្រីរដ្ឋាភិបាលដែលមានឥទ្ធិពលធំៗជាមួយក្រុមហ៊ុនប្រេងគ្រាក់ៗជាបក្ខពួករបស់ខ្លួនប៉ុណ្ណោះ។**

**ព្រោះអ្វី ? ពីព្រោះ៣០លានដុល្លារដែលរដ្ឋាភិបាល ហ៊ុន សែន យកលុយរដ្ឋថាទៅទប់ស្កាត់ កុំឱ្យប្រេងឡើងថ្លៃ ប៉ះពាល់ដល់ជីវភាពប្រជារាស្ត្រនោះ លុយទាំងនោះគឺគេយកទៅចាត់ចែងចែកឱ្យឈ្មួញ កុំឱ្យឈ្មួញខាតបាត់បង់ច្រើនដែលនាំឱ្យប៉ះពាល់ដល់ផលចំណេញដែលពួកឈ្មួញត្រូវបែងចែកជាមួយអ្នកកាន់អំណាចធំៗក្នុងរដ្ឋាភិបាលនេះ។ សាកគិតទៅមើល តម្លៃប្រេងនៅតែឡើងខ្ពស់ ហើយប៉ះពាល់ដល់ជីវភាពរបស់ប្រជារាស្ត្រ។ ដូច្នេះលុយមួយខែ៣០លានដុល្លារ តើគេយកទៅណា បើមិនមែនយកទៅចែកគ្នារវាងពួកអ្នកកាន់អំណាចធំៗ និងពួកក្រុមហ៊ុនប្រេងគ្រាក់ៗក្រោមឈ្មោះថា ឧបត្ថម្ភស្វាត់ៗកុំឱ្យប្រេងឡើងថ្លៃ ជាពាក្យដែលគេប្រើដើម្បីលួងអារម្មណ៍ប្រជារាស្ត្រកុំឱ្យក្តៅក្រហាយពីការរងគ្រោះដោយទំនិញឡើងថ្លៃនោះ ?**

**ការបញ្ចុះតម្លៃប្រេងមកនៅត្រឹមជាង៤០០០រៀល ក៏ពុំទាន់ត្រឹមត្រូវដែរ ព្រោះលោក សុន ឆ័យ សមាជិកសភាមណ្ឌលភ្នំពេញ និងជាអ្នកនាំពាក្យគណបក្សសមរង្ស៊ីធ្លាប់បានអត្ថាធិប្បាយរួចមកហើយថា "*យើងមានការព្រួយបារម្ភ និងមិនសប្បាយចិត្ត ចំពោះស្ថានភាព អំពីតម្លៃប្រេង ដូចបងប្អូនជនរួមជាតិយើងដូច្នោះដែរ ។យើងបានឃើញថាតម្លៃប្រេងនៅកម្ពុជា ដែលបានឡើងថ្លៃរហូតដល់ ៥៧០០ រៀល ក្នុងមួយលីត្រនោះ នៅពេលដែលតម្លៃប្រេងលើទីផ្សារអន្តរជាតិឡើងដល់១៤៨ដុល្លារក្នុងមួយធុង ។តែ ឥឡូវនេះ តម្លៃប្រេងធ្លាក់មកនៅក្រោម១០០ដុល្លារហើយ ក្នុងមួយធុង គឺបានន័យថាធ្លាក់តម្លៃមួយភាគបីហើយ*" ។**

**លោក *សុន ឆ័យ* បានពន្យល់ថា បើតាមតម្លៃទីផ្សារសេរីគឺ ទីផ្សារប្រេងនៅប្រទេសកម្ពុជា ត្រូវតែបញ្ចុះតម្លៃអោយនៅយ៉ាងខ្ពស់បំផុត៣៨០០រៀល ក្នុងមួយលីត្រ។ លោកបានបន្តថា រដ្ឋាភិបាលនិយាយគ្មានការ ពិតទេ ដែលកន្លងទៅមន្ត្រីរដ្ឋាភិបាលនិយាយថា មិនអាចទប់តម្លៃប្រេងឡើងថ្លៃបានទេ ពីព្រោះការឡើងនេះគឺឡើងតាមតម្លៃទីផ្សារអន្តរជាតិ ។ ប៉ុន្តែឥឡូវ ទីផ្សារអន្តរជាតិ បានចុះមួយភាគបីហើយ ហេតុអ្វីបានជាទីផ្សារនៅកម្ពុជា មិនព្រមចុះថ្លៃ ដែលនេះជាការកេងប្រវ័ញ្ច និងហុតឈាមប្រជាពលរដ្ឋខ្មែរ។ លោក*សុន ឆ័យ* បាន មានប្រសាសន៍ថា ក្រុមហ៊ុនប្រេងនៅកម្ពុជា ដូចជាក្រុមហ៊ុនសូគីម៉ិចជាដើម គឺគេបានទិញប្រេងស្តុកទុកច្រើន ដែលគេទិញនោះ តាំងពីនៅតម្លៃថោក ប៉ុន្តែគេតម្លើងថ្លៃភ្លាមឱ្យស្របតាមទីផ្សារពិភពលោកដែរ, តែនៅពេលទីផ្សារពិភពលោកចុះថ្លៃមកវិញ គេមិនចុះទេដោយគេយកលេសថា គេទិញស្តុកទុកនោះកាលពីនៅថ្លៃ។**

**លោក *សុន ឆ័យ* បានរិះគន់ រដ្ឋាភិបាលថា មិនបានពិនិត្យឱ្យបានត្រឹមត្រូវចំពោះការលក់ ប្រេងនៅលើទីផ្សារសេរី ថាតើប្រេងចាស់ ឬប្រេងទើបតែនាំ ចូលថ្មី ដើម្បីកុំឱ្យឈ្មួញចេះតែតម្លើងតម្លៃប្រេង តាមតែចិត្ត នោះ ។ លោកបានបន្តថា ការដែលរដ្ឋាភិបាលមិនធ្វើការត្រួត ពិនិត្យ ឱ្យក្រុមហ៊ុនបញ្ចុះតម្លៃប្រេង ឱ្យស្របទៅតាមទីផ្សារ អន្តរជាតិនេះ វាជាការបង្ហាញឱ្យឃើញ អំពីការគ្រប់គ្រងប្រ ទេសបែបអនាធិបតេយ្យដែលនាំឱ្យជួបការលំបាកដល់ប្រជាពលរដ្ឋ៕**

**តមកពីទំព័រ១ ខ**

អតីតនាយករដ្ឋមន្ត្រីសៀម *ថាក់ស៊ីន*ជាមួយនឹង*ហ៊ុន សែន*។

តាមប្រសាសន៍របស់លោក *សុន ឆ័យ* សមាជិកសភាជាប់ឆ្នោតថ្មីនៃគណបក្សសមរង្ស៊ី ឱ្យដឹងថា សារព័ត៌មានបរទេសមួយចំនួនបាននិយាយអំពីរឿងអាថិកំបាំងទាក់ទងនឹងគម្រោងនៃការរកស៊ីក្នុងកិច្ចសន្យាសម្ងាត់កើតមានតាំងពីសម័យ *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* កាន់តំណែងជានាយករដ្ឋមន្ត្រីសៀម ក្នុងទំនាក់ទំនងជាមួយមេដឹកនាំកម្ពុជាលោក *ហ៊ុន សែន* ។ លោក*សុន ឆ័យ* ក៏បានដកស្រង់ប្រភពនេះនិយាយអំពីគម្រោងដែលលោក *ហ៊ុន សែន* និងនាយករដ្ឋមន្ត្រីសៀមធ្លាក់ពីតំណែង *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* មានរវាងគ្នាក្នុងការធ្វើកាស៊ីណូក្បែរតំបន់ប្រាសាទព្រះវិហារ ក៏ដូចជាការអភិវឌ្ឍន៍នៃទឹកដីខ្មែរខេត្តកោះកុងនោះ។

រឿងនេះលេចឡើងដោយសារថានាយករដ្ឋមន្ត្រីសៀម ដែលទើបទទួលការតែងតាំង គឺលោក*ស៊ុមឆាយ វង់សាវ៉ាត* ដែលជាប្អូនថ្លៃ របស់លោក *ថាក់ស៊ីន* នោះអាចនឹងធ្វើឱ្យស្ថានការណ៍ធូរស្បើយឡើងវិញ ឬយ៉ាងណា ? សំណួរនេះបានលេចផុសឡើង ក៏ដោយសារតែនាយករដ្ឋមន្ត្រីសៀម ទើបចូលកាន់តំណែងថ្មីនេះជាប្អូនថ្លៃរបស់លោក *ថាក់ស៊ីន* ហើយលោក *ថាក់ស៊ីន* ក៏ធ្លាប់ត្រូវបានលោក *ហ៊ុន សែន* អះអាងថាជាក្លើម្រាក់ជិតស្និទ្ធគ្នា មានគម្រោងរកស៊ីក្នុងដើមទុនលុយជាង១ពាន់លានដុល្លារ ជាមួយគ្នានូវរបស់ដែលហៅថា ការអភិវឌ្ឍន៍កាស៊ីណូនៅជិតប្រាសាទព្រះវិហាររបស់កម្ពុជា និងនៅទឹកដីខ្មែរខេត្តកោះកុង ដែលជាប់ព្រំដែនសៀម។

តំបន់ទាំងពីរនេះក៏ត្រូវបានព្រះករុណាព្រះមហាវីរក្សត្រ សម្តេចព្រះ *នរោត្តម សីហនុ* ចេញព្រះរាជសារម្តងហើយម្តងទៀតរំលឹកឡើងនូវមហិច្ឆតារបស់ប្រទេសជិតខាង ពោលគឺសៀមចង់បានទឹកដីខ្មែរ ហើយដូច្នេះការអភិវឌ្ឍន៍នេះក៏អាចប៉ះពាល់ដល់ផែនការអ្វីជាសម្ងាត់របស់សៀម ថ្វីបើព្រះអង្គបានមានព្រះរាជបន្ទូលថា ព្រះអង្គបានត្រឹមតែថ្លែងអំណរគុណដល់អតីតនាយករដ្ឋមន្ត្រីសៀម *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* អំពីគម្រោងទាំងនេះដែលព្រះអង្គសម្តែងព្រះទ័យជាកង្វល់ព្រួយនោះ។

ក្នុងស្ថានភាពដែលកម្ពុជាបានផ្សងដេកសង្ឃឹមដោយការអូសជើងដើរតាមក្រោយនយោបាយការទូតរបស់សៀមទៅក្នុងកិច្ចចរចាទ្វេភាគីដែលពុំមានដំណោះស្រាយអ្វីនោះ អ្វីជាកង្វល់ធំគឺសៀមដូចជាបានសម្តែងនូវការប្រមាថមើលងាយដល់រចនាសម្ព័ន្ធគ្រប់គ្រងប្រទេសកម្ពុជានៃគណបក្សប្រជាជន *ហ៊ុន សែន* បច្ចុប្បន្ន។

តាមការអធិប្បាយរបស់លោក*សុន ឆ័យ* នោះថា សៀមចាប់ផ្តើមមើលងាយខ្មែរចាប់តាំងតែពីពួកគេបានបោះជំហានចូលកាន់កាប់វត្តកែវសិក្ខាគីរីស្វារៈក្នុងតំបន់ប្រាសាទព្រះវិហារ នៅថ្ងៃទី១៥ កក្កដា ពេលដែលពួកគេបានឃើញទាហានខ្មែរពាក់ស្បែកជើងផ្ទាត់ និងមានអាវុធចាស់ៗ ហើយខ្វះស្បៀងថែមទៀត ដូច្នេះបន្ថែមជាការមិនកោតញញើតរបស់ពួកគេ ហើយបណ្តាលឱ្យពួកសៀមនៅបន្តហ៊ានទន្ទ្រានចូលកាន់កាប់ដីខ្មែរមួយកន្លែងហើយ មួយកន្លែងទៀតដូចមកដល់ពេលនេះ។

តាមសេចក្តីថ្លែងរបស់លោក *សុន ឆ័យ* នោះ សៀមដូចជាស្ទង់ដឹងពីកម្លាំងនៃកងទ័ពខ្មែរនៅក្រោមអំណាចត្រួតត្រារបស់គណបក្សប្រជាជន*ហ៊ុន សែន*។ ជាឧទាហរណ៍នោះលោក *សុន ឆ័យ* ក៏បានដកស្រង់ប្រភពនៃទីភ្នាក់ងារជំនួយអន្តរជាតិកត់សម្គាល់ឃើញថា ទាហាននៅក្នុងប្រទេសកម្ពុជាមានតែក្នុងចំនួននៅក្នុងបញ្ជី ឬហៅម្យ៉ាងទៀតថា ជាទាហានខ្មោចទាំងពុំមានសម្ភារៈបរិក្ខាឱ្យមានលក្ខណៈក្លាយជាកងទ័ពរបស់ប្រទេសជាតិមួយអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទប់ទល់ចំពោះការបំពានរបស់ប្រទេសជិតខាងនោះទេ។

ជាឧទាហរណ៍ជាក់ស្តែងនោះ លោក *សុន ឆ័យ* បាននិយាយយោងដល់ប្រភពនៃរបាយការណ៍របស់ធនាគារពិភពលោកតាំងពីក្នុងអំឡុងឆ្នាំ ២០០១ ដែលនៅពេលនោះ

**តទៅទំព័រ៣ ខ**